## គោលនយោបាយទូទៅ

វាជាគោលនយោបាយរបស់ក្រុមហ៊ុន Crown Holdings, Inc. និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ដែលនាយក មន្ត្រី និងនិយោជិតគ្រប់រូបត្រូវគោរព និងប្រតិបត្តិតាមរាល់លិខិតបទដ្ឋាន និងស្មារតីនៃច្បាប់ វិធាន និងបទប្បញ្ញត្តិជាធរមាននានាគ្រប់ពេលវេលា និងគ្រប់មធ្យោបាយទាំងអស់ ហើយនិយោជិតគ្រប់រូបត្រូវព្យាយាមប្រកាន់ខ្ជាប់នូវស្តង់ដារខ្ពស់បំផុតនៃក្រមសីលធម៌ សីលធម៌ ភាពស្មោះត្រង់ និងភាពល្អប្រសើរក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

## គោលនយោបាយជាក់លាក់

ដើម្បីធានាថា និយោជិតគ្រប់រូបប្រកាន់ខ្ជាប់នូវគោលនយោបាយទូទៅ ក្រុមហ៊ុន Crown បានអនុម័តគោលនយោបាយជាក់លាក់មួយចំនួនដែលមានចែងនៅខាងក្រោម។ ទោះបីជាគោលនយោបាយជាក់លាក់ទាំងនោះមិនបានគ្របដណ្តប់គ្រប់ស្ថានភាពដែលអាចកើតឡើង ដែលនិយោជិតអាចប្រឈមមុខក៏ដោយ ក៏គោលការណ៍ជាក់លាក់ទាំងនោះដោះស្រាយបញ្ហាមួយចំនួនដែលអាចកើតឡើង។ ប្រសិនបើនិយោជិតណាម្នាក់មានចម្ងល់ថាតើការប្រព្រឹត្តដូចម្តេចត្រឹមត្រូវតាមច្បាប់ ឬត្រូវនឹងបទដ្ឋានរបស់ក្រុមហ៊ុន Crown និយោជិតនោះគួរតែសួរអ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន អ្នកគ្រប់គ្រងរោងចក្រ ឬនាយកដ្ឋានច្បាប់នៅក្នុងតំបន់របស់ខ្លួន។ លើកលែងតែមានការជូនដំណឹងផ្សេងពីនេះ គោលនយោបាយជាក់លាក់ និងឯកសារយោងទាក់ទងនឹងក្រុមហ៊ុន Crown ឬ “និយោជិត” របស់ក្រុមហ៊ុនអនុវត្តចំពោះនិយោជិត មន្ត្រី និងនាយកគ្រប់រូបរបស់ក្រុមហ៊ុន Crown Holdings, Inc. និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន។ ក្រុមហ៊ុន Crown នឹងអនុវត្តគោលនយោបាយជាក់លាក់តាមរបៀបដែលស្របតាមច្បាប់ វិធាន និងបទប្បញ្ញត្តិដែលមានជាធរមាននៅក្នុងយុត្តាធិការដែលក្រុមហ៊ុន Crown Holdings, Inc. និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនប្រកបអាជីវកម្ម។

## គោលនយោបាយស្តីពីទំនាស់ផលប្រយោជន៍ និងឱកាសសាជីវកម្ម

វាជាគោលនយោបាយរបស់ក្រុមហ៊ុន Crown ក្នុងការហាមឃាត់មិនឱ្យមានទំនាស់ផលប្រយោជន៍លើកលែងតែមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។ “ទំនាស់ផលប្រយោជន៍” កើតឡើងនៅពេលដែលផលប្រយោជន៍ឯកជនរបស់បុគ្គលប៉ះពាល់ដល់ផលប្រយោជន៍របស់ក្រុមហ៊ុន Crown។ ស្ថានភាពនៃទំនាស់អាចកើតឡើងនៅពេលដែលនិយោជិត មន្ត្រី ឬនាយកចាត់វិធានការ ឬមានផលប្រយោជន៍ដែលអាចធ្វើឱ្យមានការលំបាកក្នុងការអនុវត្តការងាររបស់ខ្លួនឱ្យក្រុមហ៊ុន Crown ដោយមិនលម្អៀង និងមានប្រសិទ្ធភាព។ ឧទាហរណ៍ ប្រសិនបើគាត់មានតួនាទីនៅក្នុងស្ថាប័នមួយដែលធ្វើអាជីវកម្ម ឬប្រកួតប្រជែងនឹងក្រុមហ៊ុន Crown។ ទំនាស់ផលប្រយោជន៍ក៏កើតមានផងដែរនៅពេលនិយោជិត មន្ត្រី ឬនាយក ឬសមាជិកគ្រួសាររបស់គាត់ទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួនមិនត្រឹមត្រូវដោយសារតែតំណែងរបស់គាត់នៅក្នុងក្រុមហ៊ុន។ និយោជិត មន្ត្រី ឬនាយករបស់ក្រុមហ៊ុន Crown ណាម្នាក់ដែលមានសំណួរទាក់ទងនឹងទំនាស់ផលប្រយោជន៍ដែលអាចកើតមានគួរតែពិគ្រោះយោបល់ជាមួយនាយកដ្ឋានច្បាប់នៅក្នុងផ្នែករបស់អ្នក។

***ឱកាសសាជីវកម្ម***

និយោជិតរបស់ក្រុមហ៊ុន Crown មានភារកិច្ចក្នុងការជំរុញផលប្រយោជន៍ស្របច្បាប់របស់ក្រុមហ៊ុន Crown នៅពេលដែលឱកាសនេះកើតឡើង ហើយត្រូវបានហាមឃាត់មិនឱ្យ៖

- ឆ្លៀតយកឱកាសផ្ទាល់ខ្លួនដែលរកឃើញតាមរយៈការប្រើប្រាស់ទ្រព្យសម្បត្តិ ព័ត៌មាន ឬមុខ តំណែង
- ប្រើប្រាស់ទ្រព្យសម្បត្តិ ព័ត៌មាន ឬមុខតំណែងរបស់សាជីវកម្មដើម្បីផលចំណេញផ្ទាល់ខ្លួន និង
- ប្រកួតប្រជែងជាមួយក្រុមហ៊ុន Crown។

***ការការពារ និងការប្រើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន***

និយោជិតរបស់ក្រុមហ៊ុន Crown គួរតែប្រឹងប្រែងការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងធានាឱ្យមានការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។ ការលួច ការធ្វេសប្រហែស និងការខ្ជះខ្ជាយដែលមានផលប៉ះពាល់ផ្ទាល់លើលទ្ធភាពរកប្រាក់ចំណេញរបស់ក្រុមហ៊ុន។ ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន Crown រួមមាន កុំព្យូទ័រ និងប្រព័ន្ធទំនាក់ទំនង និងព័ត៌មានអេឡិចត្រូនិច និងឯកសារនានា គឺត្រូវបានប្រើប្រាស់សម្រាប់តែគោលបំណងអាជីវកម្មសមស្រប និងសម្រាប់ការប្រើប្រាស់ ការចូលប្រើប្រាស់ និងសកម្មភាពនានាដែលត្រូវបានអនុញ្ញាតដោយអ្នកគ្រប់គ្រងផ្ទាល់របស់និយោជិតប៉ុណ្ណោះ។

## គោលនយោបាយជួញដូរមូលបត្រ

ការជួញដូរភាគហ៊ុន ឬមូលបត្រផ្សេងទៀតរបស់ក្រុមហ៊ុនជួញដូរជាសាធារណៈ ឬ “ការផ្តល់ព័ត៌មាន” ដល់អ្នកដទៃអំពីឯកសារ ព័ត៌មានអសាធារណៈ ត្រូវបានហាមឃាត់តាមច្បាប់របស់សហរដ្ឋអាមេរិក ហើយជាទូទៅត្រូវបានហាមឃាត់នៅក្នុងប្រទេសដទៃទៀត ហើយគួរតែជៀសវាងនូវរូបភាពណាមួយដែលនិយោជិតណាមួយរបស់ក្រុមហ៊ុន Crown ធ្វើការទិញ ឬលក់ភាគហ៊ុន ឬមូលបត្រផ្សេងទៀតរបស់ក្រុមហ៊ុន Crown (ដូចជាមូលបត្រ អតិថិជន ឬអ្នកផ្គត់ផ្គង់របស់ក្រុមហ៊ុន Crown) បានធ្វើតាមរបៀបមួយដើម្បីរកប្រាក់ចំណេញពីព័ត៌មានពីខាងក្នុងបែបនេះ។ និយោជិតរបស់ក្រុមហ៊ុន Crown មិនត្រូវបានអនុញ្ញាតឱ្យប្រើ ឬចែករំលែកឯកសារ ព័ត៌មានអសាធារណៈសម្រាប់គោលបំណងជួញដូរភាគហ៊ុនឡើយ។ ច្បាប់របស់ សហរដ្ឋអាមេរិកដែលអនុវត្តចំពោះការជួញដូររបស់អ្នកផ្ទៃក្នុង អនុវត្តមិនត្រឹមតែចំពោះភាគហ៊ុនរបស់ក្រុមហ៊ុន Crown ដែលកាន់កាប់ផ្ទាល់ដោយនិយោជិតរបស់ក្រុមហ៊ុន Crown និងគ្រួសារជិតស្និទរបស់ពួកគេផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែម

ទាំងភាគហ៊ុនរបស់ក្រុមហ៊ុន Crown ដែលជាអត្ថប្រយោជន៍របស់និយោជិត ណាមួយ ឬគណនីចូលនិវត្តន៍ដែលនិយោជិតមានសិទ្ធិ ឬសមត្ថភាពធ្វើការណែនាំពីការវិនិយោគរបស់ពួកគេ។

ព័ត៌មានផ្ទៃក្នុងមិនងាយស្រួលក្នុងការកំណត់អត្ថន័យវាបានទេ ប៉ុន្តែជាទូទៅ វាមានន័យថាជាព័ត៌មានអសាធារណៈដែលអ្នកវិនិយោគអាចប្រើប្រាស់វាដើម្បីពិចារណាធ្វើការសម្រេចចិត្តទិញកាន់កាប់ ឬលក់ភាគហ៊ុននៅក្នុងក្រុមហ៊ុនជួញដូរជាសារធារណៈ។ ដោយសារតែបទដ្ឋាននេះអាចមិនមានភាពសុក្រឹត អញ្ចឹកវាជាការប្រយ័ត្នប្រយ៉ែងក្រែងមានការច្រលំមិនទិញដូរភាគហ៊ុនក្នុងគោលបំណងកុំឲ្យមានការប្រព្រឹត្តខុសឆ្គងណាមួយកើតឡើង។

ក្រុមហ៊ុន Crown លើកទឹកចិត្តឱ្យនិយោជិតរបស់ខ្លួនវិនិយោគលើភាគហ៊ុនរបស់ក្រុមហ៊ុន Crown សម្រាប់រយៈពេលវែង។ ការជួញដូររយៈពេលខ្លីដោយនិយោជិតរបស់ក្រុមហ៊ុន Crown ជាពិសេស អាចមានលេចជារូបភាពនៃការជួញដូររបស់អ្នកខាងក្នុង។ ដូច្នេះវាជាគោលនយោបាយរបស់ក្រុមហ៊ុន Crown ក្នុងការមិនលើកទឹកចិត្តទាល់តែសោះនូវការជួញដូររយៈពេលខ្លីនូវភាគហ៊ុនរបស់ក្រុមហ៊ុន Crown។

ដើម្បីរក្សាបាននូវការប្រតិបត្តិតាមគោលនយោបាយការជួញដូរមូលបត្ររបស់ក្រុមហ៊ុន Crown ក្រុមហ៊ុន Crown តម្រូវឱ្យនិយោជិតណាដែលជាទូទៅអាចចូលប្រើប្រាស់នូវឯកសារ ព័ត៌មានអសាធារណៈ ទោះបីជាបុគ្គលនោះមិនអាចចូលប្រើប្រាស់នូវព័ត៌មានបែបនេះនៅពេលទិញ ឬលក់ក៏ដោយ បុគ្គលិកនោះត្រូវទទួលការអនុម័តសម្រាប់ការជួញដូរណាមួយពីនាយកដ្ឋានច្បាប់ជាមុនការជួញដូរ ជាក់ស្តែង។ និយោជិតរបស់ក្រុមហ៊ុន Crown ណាមួយដែលមានសំណួរអំពីការប្រព្រឹត្តត្រឹមត្រូវរបស់ខ្លួននៅក្នុងគោលនយោបាយនេះគួរតែស្វែងរកដំបូន្មានពីនាយកដ្ឋានច្បាប់របស់ក្រុមហ៊ុន Crown។

ដោយសារក្រុមហ៊ុន Crown ជាអ្នកចេញភាគហ៊ុន តាមច្បាប់ស្តីពីការគ្រប់គ្រងមូលបត្ររបស់សហរដ្ឋអាមេរិក ការហាមឃាត់ពីការជួញដូររបស់អ្នកខាងក្នុងដែលពាក់ព័ន្ធនឹងភាគហ៊ុនរបស់ក្រុមហ៊ុន Crown អនុវត្តចំពោះគ្រប់និយោជិត ភ្នាក់ងារ អ្នកគ្រប់គ្រង មន្ត្រី និងនាយកទាំងអស់របស់ក្រុមហ៊ុន Crown ទូទាំងពិភពលោក។

## គោលនយោបាយស្តីពីការជួញដូរក្រៅប្រទេស

### *<u>ការដាក់ទណ្ឌកម្ម</u>*

ក្រុមហ៊ុន Crown ត្រូវប្រតិបត្តិតាមកម្មវិធីនិងច្បាប់នៃការដាក់ទណ្ឌកម្មសេដ្ឋកិច្ចនិងពាណិជ្ជកម្ម។ ឧទាហរណ៍ ការិយាល័យសហរដ្ឋអាមេរិកនៃការត្រួតពិនិត្យទ្រព្យសម្បត្តិបរទេសត្រូវអនុវត្តការរឹតត្បិតរបស់

ខ្លួនចំពោះការធ្វើពាណិជ្ជកម្ម ជាមួយ ប្រទេស ក្រុមហ៊ុន និង បុគ្គល មួយចំនួន។

***ការប្រឆាំងការធ្វើពហិការ***

ក្រុមហ៊ុន Crown ត្រូវប្រតិបត្តិតាមច្បាប់ស្តីពីការប្រឆាំងនឹងការធ្វើពាហិកាដែលមានជាធរមាន។ ឧទាហរណ៍ ច្បាប់ស្តីពីការប្រឆាំងការធ្វើពាហិការរបស់សហរដ្ឋអាមេរិកជាទូទៅហាមឃាត់ក្រុមហ៊ុនរបស់សហរដ្ឋអាមេរិក និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទូទាំងពិភពលោកមិនឱ្យសហការជាមួយនឹងការធ្វើពាហិកាអន្តរជាតិដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកមិនដាក់ទណ្ឌកម្ម។ ការធ្វើពាហិកាកើតឡើងនៅពេលមនុស្សម្នាក់ ឬមនុស្សមួយក្រុមបដិសេធមិនធ្វើអាជីវកម្មជាមួយនឹងមនុស្ស ឬប្រទេសមួយចំនួនផ្សេងទៀត។

***ច្បាប់ស្តីពីការគ្រប់គ្រងការនាំចេញ***

ក្រុមហ៊ុន Crown ត្រូវប្រតិបត្តិតាមច្បាប់ស្តីពីការគ្រប់គ្រងការនាំចេញថ្នាក់ជាតិ និងពហុជាតិដែលមានជាធរមាន។ ឧទាហរណ៍ ច្បាប់ស្តីពីការគ្រប់គ្រងការនាំចេញរបស់សហរដ្ឋអាមេរិក អនុវត្តចំពោះការនាំចេញ និងការនាំចេញបន្តនូវទំនិញ និងបច្ចេកវិទ្យារបស់សហរដ្ឋអាមេរិក ។ ក្នុងកាលៈទេសៈមួយចំនួន ច្បាប់ទាំងនេះហាមឃាត់ក្រុមហ៊ុន និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនសហរដ្ឋអាមេរិក រួមមានក្រុមហ៊ុនដែលមានទីតាំងនៅក្រៅសហរដ្ឋអាមេរិក មិនឱ្យជួញដូរដោយផ្ទាល់ ឬដោយប្រយោលជាមួយនឹងប្រទេសមួយចំនួនដែលពាក់ព័ន្ធនឹងប្រតិបត្តិការមួយចំនួន។ និយោជិតណាមួយរបស់ក្រុមហ៊ុន Crown ដែលមានសំណួរពាក់ព័ន្ធនឹងការអនុវត្តនូវច្បាប់ស្តីពី ការដាក់ទណ្ឌកម្ម ការប្រឆាំងការធ្វើពហិការ ឬ ការគ្រប់គ្រងការនាំចេញ គួរតែពិគ្រោះយោបល់ជាមួយនឹងនាយកដ្ឋានច្បាប់នៅក្នុងផ្នែករបស់អ្នក។

## គោលនយោបាយប្រឆាំងនឹងអំពើពុករលួយ

និយោជិត មន្ត្រី នាយក ឬភាគីទីបីឯករាជ្យរបស់ក្រុមហ៊ុន Crown ដែលធ្វើសកម្មភាពក្នុងនាមក្រុម ហ៊ុនមិនអាចបង់ប្រាក់ ផ្តល់ជូន ឬសន្យាថានឹងបង់ប្រាក់ ឬអនុញ្ញាតឱ្យធ្វើការទូទាត់ទៅឱ្យភាគីសាធារណៈ ឬឯកជនណាមួយនៅក្នុងប្រទេសណាមួយ ដើម្បីធានានូវអត្ថប្រយោជន៍មិនសមរម្យសម្រាប់ក្រុមហ៊ុនឡើយ។ ពួកគេក៏មិនអាចទទួលយក ឬស្នើសុំការទូទាត់បែបនេះបានដែរ។ “ការទូទាត់” រួមបញ្ចូលទាំងសំណូក ឬការសូកប៉ាន់ ក៏ដូចជាការប្រគល់នូវអ្វីដែលមានតម្លៃមិនថាជារបស់ ឬសាច់ប្រាក់ (ដូចជា អំណោយ ការកំសាន្ត ការចំណាយការធ្វើដំណើរ ការបរិច្ចាគសប្បុរសធម៌ វិភាគទាននយោបាយ ការជួលបុគ្គល ឬសាច់ញាតិ)។

***មើលវិញ្ញាបនប័ត្រប្រឆាំងអំពើពុករលួយនិងការលាងលុយកខ្វក់របស់ Crown***

## ***អំណោយ ការបរិច្ចាគ ការកំសាន្ត និងការអនុគ្រោះ***

ក្រុមហ៊ុន Crown ទទួលស្គាល់ថា ការផ្លាស់ប្តូរម្តងម្កាលនូវការគួរសមផ្នែកអាជីវកម្ម ដូចជាអំណោយតិចតួច អាហារ និងការកម្សាន្ត (រាប់បញ្ចូលទាំងការអញ្ជើញឱ្យចូលរួមព្រឹត្តិការណ៍កីឡា

ឬពិធីជប់លៀងថ្ងៃឈប់សម្រាក) គឺជាទម្លាប់ធម្មតាមួយដែលមានគោលបំណងបង្កើតសុច្ឆន្ទៈ និងបង្កើតទំនុកចិត្តលើទំនាក់ទំនង។ ដូច្នេះ គោលនយោបាយនេះមិនមានចេតនារារាំងការផ្តល់ ឬការទទួលយកនូវការគួរសមទូទៅនោះទេ ពីព្រោះថាតម្លៃនៃការដឹងគុណគឺស្តួចស្តើងពាក់ព័ន្ធនឹងកាលៈទេសៈដែលវាត្រូវបានផ្តល់ជូន និងទទួលយក ឬស្របតាមការអនុវត្តអាជីវកម្មដែលបានទទួលយកជាទូទៅរបស់ប្រទេស និងឧស្សាហកម្ម ហើយមិនមានបំណងជះឥទ្ធិពលដល់ការសម្រេចចិត្តអាជីវកម្មរបស់បុគ្គលដែលពាក់ព័ន្ធនោះទេ។ និយោជិតគួរតែជៀសវាងការប្រព្រឹត្តណាមួយដែលសូម្បីតែបង្កើតឱ្យមានអារម្មណ៍ថាមិនសមហេតុផល។ និយោជិតដែលត្រូវបានផ្តល់ជូន ឬទទួលអំណោយជាលក្ខណៈដែលផ្ទុយនឹងគោលនយោបាយនេះគួរតែបដិសេធ ឬប្រគល់អំណោយនោះទៅវិញដោយលក្ខណៈគួរសម។

និយោជិតមិនអាចផ្តល់ឱ្យ ឬទទួលយកអ្វីដែលមានតម្លៃធំជាងតម្លៃស្តួចស្តើងទៅឱ្យ ឬពីអតិថិជនបច្ចុប្បន្ន ឬអនាគត អ្នកផ្គត់ផ្គង់ អ្នកលក់ មន្ត្រីសាធារណៈ ឬគណបក្សនយោបាយ ឬបុគ្គលផ្សេងទៀតដែលមានមុខតំណែងប្រហាក់ប្រហែលគ្នា។ ការផ្តល់ ឬការទទួលយកអំណោយជាសាច់ប្រាក់ (រួមទាំងសមមូលសាច់ប្រាក់ដូចជាភាគហ៊ុន ឬបណ្ណភាគហ៊ុន) ប្រាក់កម្ចីផ្ទាល់ខ្លួន ការបញ្ចុះតម្លៃ ឬអំណោយ ឬការអនុគ្រោះណាមួយផ្សេងទៀតដែលអាចត្រូវបានចាត់ទុកថាជាសំណូក ឬការសូកប៉ាន់ ឬការទូទាត់ខុសច្បាប់ ឬអសីលធម៌ផ្សេងទៀត ត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹងដោយមិនគិតពីតម្លៃឡើយ។ លើសពីនេះ និយោជិតរបស់ក្រុមហ៊ុន Crown មិនអាចស្នើសុំអំណោយ ការដឹងគុណ ឬការអញ្ជើញទទួលទានអាហារ ឬការកម្សាន្តពីអ្នកណាម្នាក់ដែលក្រុមហ៊ុន Crown ធ្វើអាជីវកម្ម ឬកំពុងចរចាធ្វើអាជីវកម្មឡើយ។ ទោះក្នុងកាលៈទេសៈណាក៏ដោយ មូលនិធិសាជីវកម្មរបស់ក្រុមហ៊ុន Crown មិនអាចត្រូវបានប្រើប្រាស់ដោយខុសច្បាប់សម្រាប់ការចូលរួមចំណែកនយោបាយប្រភេទណាមួយឡើយ។

គោលនយោបាយនេះមានគោលបំណងអនុវត្តចំពោះនិយោជិត មន្ត្រី និងនាយកទាំងអស់របស់ក្រុមហ៊ុនCrown និងសមាជិកគ្រួសារជិតស្និតរបស់ពួកគេក៏ដូចជាភាគីទីបីឯករាជ្យក្នុងនាមក្រុមហ៊ុនដែលរួមមានភ្នាក់ងារភាគីទីបី អ្នកចែកចាយ អ្នកពិគ្រោះយោបល់ អ្នកម៉ៅការ និងអ្នកបញ្ចុះបញ្ចូល និងដៃគូ វិនិយោគរួមគ្នារបស់ក្រុមហ៊ុន Crown។ សូមមើលសៀវភៅណែនាំស្តីពីគោល

នយោបាយប្រឆាំងនឹងអំពើពុករលួយរបស់ក្រុមហ៊ុន Crown សម្រាប់ព័ត៌មានលម្អិតបន្ថែម និងឧទាហរណ៍នានានៃបញ្ហាដែលអាចកើតមាន។ ប្រសិនបើអ្នក ដែលត្រូវបានរាប់បញ្ចូល មានសំណួរណាមួយទាក់ទងនឹងការអនុវត្តគោល នយោបាយនេះ បុគ្គលនោះគួរតែបង្ហាញពីកាលៈ

ទេសៈដែលពាក់ព័ន្ធ និងស្វែងរកការយល់ព្រមពីប្រធានផ្នែកពាក់ព័ន្ធ ឬពីនាយកដ្ឋានច្បាប់របស់ក្រុមហ៊ុន Crown។

## គោលនយោបាយច្បាប់ស្តីពីការបំពានលើទំនុកចិត្ត (ANTITRUST) និងការប្រកួតប្រជែង

ក្រុមហ៊ុន Crown ប្រកួតប្រជែងដោយស្វាហាប់ យុត្តិធម៌ និងឯករាជ្យដើម្បីអាជីវកម្មតាមរបៀបប្រកបដោយក្រមសីលធម៌នៅគ្រប់តំបន់នៃទីផ្សារទាំងអស់សម្រាប់ផលិតផលរបស់ក្រុមហ៊ុន Crown។ ច្បាប់ស្តីពីការទប់ទល់នឹងគ្រឹស្ត និងការប្រកួតប្រជែងរបស់បណ្តាប្រទេសដែលក្រុមហ៊ុន Crown ធ្វើអាជីវកម្មគឺជាគ្រឹះនៃសហគ្រាសប្រកួតប្រជែងដោយសេរី។

ក្រុមហ៊ុន Crown តម្រូវឱ្យនិយោជិតទាំងអស់ប្រតិបត្តិតាមយ៉ាងពេញលេញនូវច្បាប់ស្តីពីការ

បំពានលើទំនុកចិត្ត និងការប្រកួតប្រជែងរបស់បណ្តាប្រទេសដែលក្រុមហ៊ុន Crown ធ្វើអាជីវកម្ម។ វាជារឿងខុសច្បាប់នៅក្នុងសហរដ្ឋអាមេរិក និងប្រទេសជាច្រើនទៀតដែលក្រុមហ៊ុន Crown ធ្វើអាជីវកម្មដើម្បីចុះកិច្ចព្រមព្រៀង ការយោគយល់ ឬការពិភាក្សាជាមួយដៃគូប្រកួតប្រជែងរបស់យើងទាក់ទងនឹង៖ តម្លៃឬការបញ្ចុះតម្លៃ លក្ខន្តិកៈនៃការលក់ រួមមានលក្ខខណ្ឌឥណទាន ប្រាក់ចំណេញកម្រិតប្រាក់ចំណេញ ឬតម្លៃ ចំណែកទីផ្សារ ការអនុវត្ត ឬបណ្តាញចែកចាយ ការដេញថ្លៃ ឬចេតនាដេញថ្លៃ ពង្រីកសមត្ថភាព ឬចូលទីផ្សារថ្មី ការជ្រើសរើស ការចាត់ថ្នាក់ ការបដិសេធ ឬការបញ្ចប់អតិថិជន ឬប្រភេទអតិថិជន ដែនដីនៃការលក់ ឬទីផ្សារ ការផ្លាស់ប្តូរព័ត៌មានប្រកួតប្រជែង ឬបញ្ហាផ្សេងៗណាមួយដែលមិនស៊ីចង្វាក់នឹងសេរីភាពពេញលេញនៃសកម្មភាព និងឯករាជ្យភាពរបស់ក្រុមហ៊ុនក្នុងការធ្វើអាជីវកម្មរបស់ខ្លួនឡើយ។

ប្រធានប្រចាំតំបន់ និងអនុប្រធានផ្នែកលក់ និងនាយកដ្ឋានច្បាប់ចែករំលែកការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន Crown ក្នុងការប្រតិបត្តិតាមច្បាប់ស្តីពីការទប់ទល់នឹងគ្រឹស្ត និងការប្រកួតប្រជែង។ សូមពិគ្រោះជាមួយពួកគេមុននឹងផ្តល់ការបញ្ចុះតម្លៃផ្សេងៗ ប្រាក់ត្រលប់មកវិញ ប្រាក់ឧបត្ថម្ភឬការកែប្រែតម្លៃផ្សេងៗទៀត ឬលក្ខខណ្ឌ ឬលក្ខន្តិកៈផ្សេងនៃការលក់ជូនអតិថិជនផ្សេងៗគ្នាសម្រាប់

ផលិតផលតែមួយ ឬប្រសិនបើអ្នកមានសំណួរ ឬកង្វល់ណាមួយ និងរាល់ពេលដែលអ្នកត្រូវការជំនួយក្នុងការស្វែងយល់ ឬប្រតិបត្តិតាមគោលនយោបាយនេះ។

## គោលនយោបាយស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាព

ក្រុមហ៊ុន Crown ទទួលស្គាល់ថា ការការពារសុខភាពមនុស្ស និងបរិស្ថានគឺជាការអនុវត្តអាជីវកម្មដ៏ត្រឹមត្រូវមួយដែលអភិរក្សធនធាន និងការពារនិយោជិត អតិថិជន សាធារណជន និងបរិស្ថានទូទៅ។ និយោជិតរបស់ក្រុមហ៊ុន Crown គ្រប់រូបចែករំលែកការទទួលខុសត្រូវនេះក្នុងការធានាភាពជោគជ័យរយៈពេលវែងរបស់ក្រុមហ៊ុន Crown។

ដើម្បីអនុវត្តនូវគោលនយោបាយនេះ ក្រុមហ៊ុន Crown និងនិយោជិតរបស់ខ្លួនត្រូវ៖

- ប្តេជ្ញាចិត្តចំពោះភាពជាអ្នកដឹកនាំដោយប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន Crown ស្របតាមលក្ខខណ្ឌតម្រូវរបស់បទប្បញ្ញត្តិទាំងអស់ និងបទដ្ឋាន និងគោលនយោបាយស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់ក្រុមហ៊ុន Crown។
- ពង្រឹងវប្បធម៌បុរេសកម្មផ្នែកបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់ក្រុមហ៊ុន Crown ដោយបង្កើនការយល់ដឹង និងចំណេះដឹងក្នុងចំណោមនិយោជិតគ្រប់លំដាប់ថ្នាក់ និងប្តេជ្ញាចំពោះការការពារ និងសុខុមាលភាពរបស់និយោជិតគ្រប់រូប។
- លើកកម្ពស់ការការពារការបំពុលដោយផ្តោតលើការកាត់បន្ថយប្រភព និងការអភិរក្សធនធាននិងរួមបញ្ចូលការពិចារណាពីបរិស្ថាន សុខភាព និងសុវត្ថិភាពក្នុងចំណោមលក្ខណៈវិនិច្ឆ័យការវាយតម្លៃគម្រោង ផលិតផល ដំណើរការ និងការទិញ។
- តម្រូវឱ្យនិយោជិតគ្រប់រូបទទួលខុសត្រូវចំពោះ សន្តិសុខការងារ ពាក់ព័ន្ធនឹងបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់ខ្លួន មិត្តរួមការងារ និងក្រុមហ៊ុន។
- វាយតម្លៃការអនុវត្តការងារ និងកម្មវិធីពាក់ព័ន្ធនិងបរិស្ថាន សុខភាពនិងសុវត្ថិភាព និងប្តេជ្ញាកែលម្អជាបន្តឆ្ពោះទៅគោលដៅកំណត់ដែលគ្មានគ្រោះថ្នាក់ និងគ្មានផលប៉ះពាល់។

## គោលនយោបាយស្តីពីការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានសម្ងាត់

### ***<u>ព័ត៌មានអាជីវកម្ម</u>***

និយោជិតរបស់ក្រុមហ៊ុន Crown ដោះស្រាយរៀងរាល់ថ្ងៃជាមួយព័ត៌មានអំពីក្រុមហ៊ុន និង

អាជីវកម្មរបស់ខ្លួន។ ព័ត៌មាននេះរួមមានផែនការអាជីវកម្ម ដំណើរការផលិតកម្ម និងបច្ចេកវិទ្យា ការធ្វើទីផ្សារ និង ព័ត៌មានតម្លៃបញ្ជីអតិថិជន និងផែនការសម្រាប់អាជីវកម្ម និងការបណ្តាក់ទុនថ្មីៗ។ អាជីវកម្មរបស់ក្រុមហ៊ុន Crown អាចនឹងត្រូវខូចខាត ប្រសិនបើព័ត៌មាននេះត្រូវបានបង្ហាញដល់ដៃគូប្រកួតប្រជែង ឬទៅអ្នកណាម្នាក់ផ្សេងទៀតនៅក្រៅក្រុមហ៊ុននោះ។

និយោជិតនីមួយៗរបស់ក្រុមហ៊ុន Crown ត្រូវសន្មតថា រាល់ព័ត៌មានទាំងអស់នោះគឺជាការសម្ងាត់ (លើកលែងតែកាលៈទេសៈដែលក្រុមហ៊ុន Crown បានបង្ហាញព័ត៌មាននៅក្នុងរបាយការណ៍ដែលបាន ផ្សព្វផ្សាយ ឬនៅពេលដែលនិយោជិតអាចផ្ទៀងផ្ទាត់ថាព័ត៌មាននោះត្រូវបានដឹងជាសាធារណៈ)។ ដូចគ្នានេះដែរ និយោជិតនីមួយៗរបស់ក្រុមហ៊ុន Crown គួរសន្មតថារាល់ព័ត៌មានដែលបានបង្ហាញដល់ក្រុមហ៊ុន Crown ដោយអតិថិជន និងអ្នកផ្គត់ផ្គង់របស់ខ្លួនគឺជាការសម្ងាត់ (លើកលែងតែកាលៈទេសៈដែលអតិថិជន ឬអ្នកផ្គត់ផ្គង់បានយល់ស្របច្បាស់លាស់ចំពោះការបង្ហាញព័ត៌មានរបស់ខ្លួន ឬនិយោជិតអាចផ្ទៀងផ្ទាត់ថា ព័ត៌មានត្រូវបានដឹងជាសាធារណៈ)។ និយោជិតម្នាក់ៗរបស់ក្រុមហ៊ុន Crown មានកាតព្វកិច្ចក្នុងអំឡុងពេល និងក្រោយពេលបំពេញការងាររបស់ខ្លួនក្នុងការរក្សាព័ត៌មានសម្ងាត់ទាំងអស់ដោយភាពជឿជាក់ ក្នុងការបដិសេធមិនបង្ហាញព័ត៌មានបែបនេះដល់មនុស្សណាម្នាក់នៅខាងក្រៅក្រុមហ៊ុនដោយគ្មានការយល់ព្រមពីក្រុមហ៊ុនជាមុន ហើយក្នុងការបដិសេធមិនប្រើប្រាស់ព័ត៌មានបែបនេះសម្រាប់គោលបំណងផ្សេងទៀតក្រៅពីការអនុវត្តភារកិច្ចរបស់ខ្លួនចំពោះក្រុមហ៊ុន លើកលែងតែនៅពេលដែលការបង្ហាញព័ត៌មាននេះចាំបាច់ដោយអនុលោមតាមច្បាប់ជាធរមាន។ អ្វីៗនៅក្នុងគោលនយោបាយនេះ ឬកិច្ចព្រមព្រៀងផ្សេងទៀតជាមួយក្រុមហ៊ុន Crown ទាក់ទងនឹងបញ្ហារក្សាការសម្ងាត់ នឹងត្រូវបង្អាមិនឲ្យនិយោជិតរបស់ក្រុមហ៊ុន Crown រាយការណ៍ពីការរំលោភបំពានទៅកាន់អាជ្ញាធររដ្ឋាភិបាល ឬធ្វើឱ្យមានការបង្ហាញព័ត៌មានផ្សេងទៀតដែលត្រូវបានការពារក្រោមបទបញ្ញត្តិអ្នករាយការណ៍សម្ងាត់របស់ច្បាប់ជាធរមានបានឡើយ។

## ***ព័ត៌មានផ្ទាល់ខ្លួន***

ទិន្នន័យផ្ទាល់ខ្លួនត្រូវប្រមូល និងរក្សាទុកដោយសម្ងាត់ដែលធានាថាទិន្នន័យទាំងនោះអាចប្រើប្រាស់បានលុះត្រាតែអនុលោមតាមច្បាប់ជាធរមាន និងសម្រាប់តែបុគ្គលទាំងឡាយណាដែលមានសិទ្ធ ស្របច្បាប់ត្រូវការដឹងពីទិន្នន័យទាំងនោះប៉ុណ្ណោះ។

# គោលនយោបាយស្តីពីឱកាសការងារស្មើភាពគ្នា ការរើសអើង និងការបៀតបៀន

និយោជិតទាំងអស់មានសិទ្ធិទទួលបានការប្រព្រឹត្តដោយសេចក្តីគោរព និងសេចក្តីថ្លៃថ្នូរ គឺដើម្បីធ្វើការក្នុងបរិយាកាស ដោយគ្មានការរើសអើងក្នុងការងារមិនស្របច្បាប់គ្រប់ទម្រង់ទាំងអស់ រួមទាំងការបៀតបៀនផ្លូវភេទ និងការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត សញ្ជាតិ ជាតិ

សាសន៍ សាសនា អាយុ ភេទ យេនឌ័រ (ទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ ឬការបញ្ចេញមតិ) ពិការភាពរាងកាយ ឬផ្លូវចិត្ត ព័ត៌មានសេនេទិក សេវាឯកសណ្ឋាន ស្ថានភាពយុទ្ធជន ឬ លក្ខណៈផ្សេងទៀតដែលការពារដោយច្បាប់ ឬមូលដ្ឋាន បញ្ញត្តិ ឬបទប្បញ្ញត្តិ។ ដូច្នេះវាជាគោលនយោបាយរបស់ក្រុមហ៊ុន Crown ដែលថាការរើសអើងមិនស្របច្បាប់ រួមទាំងការបៀតបៀនក្នុងទម្រង់ណាមួយ ដែលប្រព្រឹត្តមកលើ និយោជិតដោយអ្នកគ្រប់គ្រងផ្ទាល់ មិត្តរួមការងារ អ្នកលក់ ឬអតិថិជនរបស់ពួកគេត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹង។ ការប្រព្រឹត្តបែបនេះក៏មិនត្រូវបានគេអត់ឱនឱ្យដែរ ហើយគួរតែត្រូវបានរាយការណ៍ភ្លាមៗដូចមានចែងនៅក្នុងគោលនយោបាយនេះ។ វាក៏ជាគោលនយោបាយរបស់ក្រុមហ៊ុនCrown ផងដែរដែលមិនរើសអើងចំពោះអ្នកដាក់ពាក្យសុំបម្រើការងារណាមួយលើមូលដ្ឋានដែលបានពិពណ៌នាខាងលើ។

សម្រាប់គោលបំណងនៃគោលនយោបាយនេះ ការបៀតបៀនត្រូវបានកំណត់ថាជាការប្រព្រឹត្តដោយពាក្យសំដី ឬរាងកាយដែលបង្អាក់ ឬបង្ហាញនូវអរិភាព ឬការស្អប់ខ្ពើមចំពោះបុគ្គលម្នាក់ដោយហេតុផលណាមួយដែលបានរៀបរាប់ខាងលើ និងដែល៖

- មានគោលបំណង ឬផលប៉ះពាល់ក្នុងការបង្កើតនូវបរិស្ថានការងារដែលមានការគំរាមកំហែង អរិភាព ឬរំលោភបំពាន
- មានគោលបំណង ឬផលប៉ះពាល់មិនសមហេតុផលក្នុងការបំពេញការងាររបស់បុគ្គល ឬ
- មានផលប៉ះពាល់អាក្រក់ដល់ឱកាសការងាររបស់បុគ្គល។

ឧទាហរណ៍មួយចំនួននៃការបៀតបៀនបែបនេះគឺ៖ ការប្រើឈ្មោះហៅក្រៅ ពាក្យចោទ ឬប្រភេទ លក្ខណៈអវិជ្ជមាន។ ការគំរាមកំហែង បំភិតបំភ័យ ឬការចូលរួមក្នុងសកម្មភាពអរិភាពទាក់ទងទៅនឹងលក្ខណៈការពារ។ ការបង្អាប់របៀបកំប្លែងលេងសើច ឬការបញ្ឆោត។ ការបិទលើជញ្ជាំង ក្តារព្រឹត្តិបត្រ ឬកន្លែងផ្សេងទៀតនៅតាមបរិវេណក្រុមហ៊ុន (ឬផ្សព្វផ្សាយនៅកន្លែងធ្វើការតាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយ) ផ្ទាល់មាត់ ការសរសេរ ឬក្រាហ្វិកដែលបង្អាប់ ឬបង្ហាញនូវអរិភាព ឬការស្អប់ខ្ពើមចំពោះបុគ្គល ឬក្រុម ដោយសារតែលក្ខណៈការពារទាំងនេះ។

## គោលនយោបាយស្តីពីការជួញដូរដោយយុត្តធម៌ និងការពិតនៅក្នុងរបាយការណ៍ និងកំណត់ត្រា

និយោជិតរបស់ក្រុមហ៊ុន Crown គួរប្រឹងប្រែងប្រាស្រ័យទាក់ទងដោយស្មើភាពជាមួយអតិថិជន អ្នកផ្គត់ផ្គង់គូប្រកួតប្រជែង និងនិយោជិតរបស់ក្រុមហ៊ុន។ និយោជិតរបស់ក្រុមហ៊ុន Crown ត្រូវបានហាមឃាត់មិនឱ្យទាញយកផលប្រយោជន៍ពីអ្នកណាម្នាក់ដោយអយុត្តិធម៌តាមរយៈឧបាយកល ការលាក់បាំង ការប្រើប្រាស់ព័ត៌មានឯកសិទ្ធិ ការបង្ហាញមិនត្រឹមត្រូវនូវព័ត៌មានសំខាន់ៗ ឬការអនុវត្តមិនយុត្តិធម៌ផ្សេងៗ។

និយោជិតរបស់ក្រុមហ៊ុន Crown មិនត្រូវបង្កើត រក្សាទុក ឬបញ្ជូនដោយចេតនានូវកំណត់ត្រា របាយការណ៍ ឬសេចក្តីថ្លែងការណ៍ដែលមិនត្រឹមត្រូវ ក្លែងក្លាយ ឬបំភាន់ឡើយ។ និយោជិតរបស់ក្រុមហ៊ុន Crown ទាំងអស់មានកាតព្វកិច្ចបញ្ជាក់ដើម្បីធានាថាសេចក្តីថ្លែងការណ៍ ឬតំណាងណាមួយដែលបានធ្វើឡើងក្នុងនាមក្រុមហ៊ុន Crown គឺជាការពិត និងត្រឹមត្រូវ។ នៅពេលដែលគោលនយោបាយនេះអនុវត្តចំពោះរាល់ការប្រាស្រ័យទាក់ទងដែលធ្វើនៅក្នុងនាមក្រុមហ៊ុនCrownវាមានសារៈសំខាន់ជាពិសេស ទាក់ទងនឹងសេចក្តីថ្លែងការណ៍ លិខិត ឬឯកសារណាមួយដែលត្រូវប្រគល់ផ្ទាល់ទៅឱ្យទីភ្នាក់ងាររដ្ឋាភិបាលណាមួយ ដោយផ្អែកលើការទាយឬប៉ាន់ស្មាននោះទេ។

ការក្លែងបន្លំនៅក្នុងកំណត់ត្រា សំណើសុំ ឬសេចក្តីថ្លែងការណ៍គឺជាប្រភេទនៃការប្រព្រឹត្តដែលទំនងខ្លាំងនឹងបង្កឱ្យមានការរំលោភបំពានច្បាប់ក៏ដូចជាការលេចឡើងនូវរូបភាពមិនត្រឹមត្រូវ។ បុគ្គលដែលបំពេញ ឬដែលទទួលខុសត្រូវ ឬដែលធ្វើសេចក្តីថ្លែងការណ៍ទៅកាន់ទីភ្នាក់ងាររដ្ឋាភិបាល ឬស្ថាប័នដែលមានបទប្បញ្ញត្តិត្រូវតែយកចិត្តទុកដាក់ដើម្បីធានាថាកំណត់ត្រា ឬសេចក្តីថ្លែងការណ៍ទាំងនោះមានភាពត្រឹមត្រូវ។ ក្នុងន័យនេះ វាជាការល្អក្នុងការនិយាយការពិត និងទទួលស្គាល់ភាពមិនដឹងក្នុងករណីមិនច្បាស់ជាជាងការស្មាន។ ដូចគ្នានេះដែរ និយោជិតរបស់ក្រុមហ៊ុន Crown គួរតែពិនិត្យការពិតជានិច្ចដើម្បីប្រាកដថាពួកគេមានភាពត្រឹមត្រូវជាជាងការផ្តល់ព័ត៌មាន ឬរបាយការណ៍ទៅកាន់ទីភ្នាក់ងាររដ្ឋាភិបាល ឬស្ថាប័នដែលមានបទប្បញ្ញត្តិដោយផ្អែកលើការស្មាន ឬការសន្មត។

## គោលនយោបាយស្តីពីរបាយការណ៍ហិរញ្ញវត្ថុ

នាយកប្រតិបត្តិ នាយកហិរញ្ញវត្ថុ អ្នកត្រួតពិនិត្យ និងសមាជិកទាំងអស់នៃនាយកដ្ឋានហិរញ្ញវត្ថុ របស់ក្រុមហ៊ុន Crown ដែលមានការទទួលខុសត្រូវរាយការណ៍ពីហិរញ្ញវត្ថុត្រូវៈ

- ចូលរួម និងលើកកម្ពស់ការប្រព្រឹត្តដោយភាពស្មោះត្រង់ និងក្រមសីលធម៌ រួមទាំងការ

ដោះស្រាយប្រកបដោយក្រមសីលធម៌រវាងទំនាក់ទំនងផ្ទាល់ខ្លួននិងវិជ្ជាជីវៈនូវទំនាស់ផលប្រយោជន៍ ជាក់ស្តែង ឬដែលលេចចេញមក។

- លើកកម្ពស់ការបង្ហាញព័ត៌មានពេញលេញ យុត្តិធម៌ ត្រឹមត្រូវ ទាន់ពេលវេលា និងអាចយល់បាននៅក្នុងរបាយការណ៍ និងឯកសារនានាដែលក្រុមហ៊ុន Crown ដាក់ជាមួយ ឬដាក់ជូនទៅគណៈកម្មការមូលបត្រសហរដ្ឋអាមេរិក និងក្នុងការទំនាក់ទំនងសាធារណៈផ្សេងទៀត។
- ប្រតិបត្តិតាមច្បាប់ វិធាន និងបទប្បញ្ញត្តិដែលមានជាធរមាន។
- រាយការណ៍ភ្លាមៗអំពីការរំលោភបំពានណាមួយនៃក្រមសីលធម៌ និងសីលធម៌អាជីវកម្មនេះទៅកាន់អគ្គមេធាវី ឬទំនាក់ទំនងណាមួយដែលបានរាយបញ្ជីនៅទីនេះ និង
- ទទួលខុសត្រូវចំពោះការប្រកាន់ខ្ជាប់នូវក្រមសីលធម៌ខាងលើ។

## ភារកិច្ចរបស់និយោជិត

និយោជិតរបស់ក្រុមហ៊ុន Crown ទាំងអស់ ចាប់តាំងពីគណៈគ្រប់គ្រងប្រតិបត្តិរហូតដល់គណៈគ្រប់គ្រងរោងចក្ររហូតដល់និយោជិតគិតម៉ោង និងក្រៅម៉ោងទាំងអស់ត្រូវអនុវត្តតាមគោលនយោបាយដែលមានចែងក្នុងក្រមនេះ។ លើសពីនេះទៅទៀត និយោជិតរបស់ក្រុមហ៊ុន Crown ទាំងអស់ត្រូវតែគោរពច្បាប់ វិធាន និងបទប្បញ្ញត្តិជាធរមានទាំងអស់គ្រប់ពេលវេលាដោយមិនគិតពីការអនុវត្តក្នុងតំបន់ឬឧស្សាហកម្មអ្វីដែលអាចមាននៅក្នុងវិស័យណាមួយឡើយ។ ការខកខានមិនបានគោរពតាមគោលនយោបាយទាំងនេះអាចបណ្តាលឱ្យមានការវិន័យ រហូតដល់ និងរួមទាំងការបណ្តេញចេញផងដែរ។

និយោជិតរបស់ក្រុមហ៊ុន Crown ណាម្នាក់ដែលមានសំណួរអំពីថាតើសកម្មភាពជាក់លាក់មួយដែលខ្លួនកំពុងពិចារណា ឬស្ថានភាពដែលខ្លួនមានការពាក់ព័ន្ធជាមួយអាចមិនត្រូវគ្នានឹងគោលនយោបាយរបស់ក្រុមហ៊ុន ឬអាចមិនត្រឹមត្រូវសម្រាប់ហេតុផលផ្សេងណាមួយ គួរតែលើកសំណួរនោះពិភាក្សាជាមួយអ្នកគ្រប់គ្រងផ្ទាល់របស់ពួកគេ អ្នកគ្រប់គ្រងរោងចក្រ ឬការិយាល័យប្រតិបត្តិតាម និងដោះស្រាយឱ្យបានមុនពេលចាត់វិធានការ ឬអនុញ្ញាតឱ្យស្ថានការណ៍នោះបន្តមានទៀត។

## ការប្រតិបត្តិតាម និងនីតិវិធីរាយការណ៍

បុគ្គលិកគ្រប់គ្រងមួយចំនួននឹងតម្រូវឱ្យដាក់បញ្ចូលជាទៀងទាត់នូវការបញ្ជាក់ដែលមានចុះហត្ថលេខាដែលសបញ្ជាក់ថា ពួកគាត់ដឹងពីគោលនយោបាយនៃក្រមសីលធម៌ និងសីលធម៌អាជីវកម្មរបស់ក្រុមហ៊ុន Crown ហើយបានសង្កេតនូវក្រមសីលធម៌ និងសីលធម៌ទាំងនោះ ហើយមិនបាន

ដឹងអំពីការរំលោភបំពានគោលនយោបាយណាមួយឡើយ។ និយោជិតណាមួយដែលដឹងអំពីការរំលោភបំពានណាមួយនៃក្រមសីលធម៌នេះ ត្រូវតែរាយការណ៍ភ្លាមៗពីការរំលោភបំពាននេះទៅអ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន អ្នកគ្រប់គ្រងរោងចក្រ ឬទៅការិយាល័យប្រតិបត្តិតាម។

និយោជិតណាដែលរាយការណ៍អំពីការរំលោភបំពាននឹងត្រូវបានប្រព្រឹត្ត ដោយសេចក្តីថ្លៃថ្នូរ និងការគោរព ហើយនឹងមិនត្រូវបានទទួលរងនូវការវិន័យឬការសងសឹកទម្រង់ណាមួយឡើយ ចំពោះរបាយការណ៍ដែលធ្វើដោយភាពស្មោះត្រង់។ និយោជិតណាដែលគិតថា ខ្លួនកំពុងត្រូវបានប្រព្រឹត្តចំពោះដោយអយុត្តិធម៌ដែលជាលទ្ធផលនៃការធ្វើរបាយការណ៍បែបនេះគួរតែរាយការណ៍អំពីបញ្ហានេះទៅការិយាល័យកណ្តាល ឬការិយាល័យប្រតិបត្តិតាមតំបន់។ បុគ្គលណាដែលត្រូវបានគេរកឃើញថា បានសងសឹក ឬតាមដាក់ទណ្ឌកម្មតាមរបៀបណាមួយដល់និយោជិតម្នាក់ទៀតបានរាយការណ៍អំពីការរំលោភបំពានដោយភាពស្មោះត្រង់ នឹងត្រូវទទួលការវិន័យ រហូតដល់និងរួមបញ្ចូលទាំងការបណ្តេញចេញ។

***មន្ត្រីផ្នែកប្រតិបត្តិតាម***

ក្រុមហ៊ុន Crown បានតែងតាំងមន្ត្រីប្រតិបត្តិតាមដូចខាងក្រោម៖

ការិយាល័យកណ្តាល និងតំបន់អាមេរិក

Adam Dickstein
Senior Vice President General Counsel and Corporate Secretary

Michael Rowley
Assistant General Counsel

ផ្នែកអឺរ៉ុប

Jean-Francois Lelouch
Assistant General Counsel

ផ្នែកអាស៊ីប៉ាស៊ីហ្វិច

Ee Ping Han
Legal Director

ការិយាល័យប្រតិបត្តិតាមទទួលខុសត្រូវចំពោះគ្រប់ទិដ្ឋភាពនៃការប្រតិបត្តិតាមសម្រាប់ការបង្កើត និងកែប្រែគោលនយោបាយដែលមានចែងក្នុងសៀវភៅណែនាំនេះ និងសម្រាប់ការអនុវត្តនីតិវិធីដែលបានរៀបចំឡើងដើម្បីសម្រេចបាននូវគោលនយោបាយទាំងនេះ។

## *របៀបរាយការណ៍ពីការរំលោភបំពាន*

និយោជិតរបស់ក្រុមហ៊ុន Crown ទាំងអស់ត្រូវរាយការណ៍ភ្លាមៗនូវរាល់ការរំលោភបំពានលើគោលនយោបាយ និងនីតិវិធីដែលមានចែងក្នុងសៀវភៅណែនាំនេះ។ និយោជិតរបស់ក្រុមហ៊ុន Crown ណាមួយដែលមានសេចក្តីស្មោះត្រង់ក្នុងការរាយការណ៍ពីការរំលោភលើគោលនយោបាយ

ឬនីតិវិធីទាំងនេះមិនអាចត្រូវបានដាក់ទណ្ឌកម្ម ឬសងសឹកក្នុងទម្រង់ណាមួយឡើយ។

និយោជិតគ្រប់រូបដែលដឹងពីការរំលោភបំពាននូវគោលនយោបាយ ឬនីតិវិធីប្រតិបត្តិតាមមានវិធីបីយ៉ាងក្នុងការរាយការណ៍៖ ទៅកាន់ (១) អ្នកគ្រប់គ្រងផ្ទាល់របស់ពួកគេ )២ (អ្នកគ្រប់គ្រងរោងចក្រ ឬអ្នកដែលមានឋានៈស្មើ ឬ (៣) ការិយាល័យប្រតិបត្តិតាម។

និយោជិតគ្រប់រូប ដំបូងគួរតែរាយការណ៍អំពីការរំលោភបំពានទៅកាន់អ្នកគ្រប់គ្រងផ្ទាល់របស់ពួកគេជាមុនសិន។ប្រសិនបើនិយោជិតមានអារម្មណ៍ស្ទាក់ស្ទើរក្នុងមធ្យោបាយណាមួយក្នុងការរាយការណ៍អំពីការរំលោភបំពានទៅកាន់អ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន។ (ឧទាហរណ៍ ប្រសិនបើអ្នកគ្រប់គ្រងផ្ទាល់របស់ពួកគេពាក់ព័ន្ធនឹងការរំលោភបំពានដោយផ្ទាល់) និយោជិតអាចរាយការណ៍ពីការរំលោភបំពានទៅអ្នកគ្រប់គ្រងរោងចក្រ ឬទៅការិយាល័យប្រតិបត្តិតាម។ ក្នុងករណីណាក៏ដោយ និយោជិតដែលមានចិត្តស្មោះត្រង់ធ្វើការរាយការណ៍អាចមិនត្រូវបានដាក់ទណ្ឌកម្ម ឬសងសឹកចំពោះការធ្វើការរាយការណ៍នេះឡើយ។

ដើម្បីរាយការណ៍ពីការរំលោភបំពានដែលសង្ស័យទៅការិយាល័យប្រតិបត្តិតាមរបស់ក្រុមហ៊ុន Crown និយោជិតអាចសរសេរ ឬទូរសព្ទទៅកាន់មន្ត្រីប្រតិបត្តិតាមដូចខាងក្រោម៖

Adam Dickstein
Crown Holdings, Inc.
770 Township Line Road
Yardley, PA 19067
800-523-3644 Ext. 5576
adam.dickstein@crowncork.com

Michael Rowley
Crown Holdings, Inc.
770 Township Line Road
Yardley, PA 19067
800-523-3644 Ext. 3756
mike.rowley@crowncork.com

Jean-Francois Lelouch
Crown Packaging European Division Services SAS
7 rue Emmy Noether
93400 Saint-Ouen
France
+33 (1) 49 18 40 81
jean-francois.lelouch@eur.crowncork.com

Ee Ping Han
CROWN Asia Pacific Holdings Pte. Ltd.
1 HarbourFront Place #03-01
HarbourFront, Tower One
Singapore  098633
+65 6423 9798
ee-ping.han@crowncork.com.sg

លើសពីនេះ រាល់បណ្តឹងតវ៉ាទាំងឡាយណាដែលទាក់ទងនឹងគណនេយ្យ ការគ្រប់គ្រងផ្ទៃក្នុង ឬបញ្ហាសវនកម្មក៏គួរតែត្រូវបានទាក់ទងទៅការិយាល័យប្រតិបត្តិ តាមអាសយដ្ឋាន ឬលេខទូរសព្ទដែលបានរៀបរាប់ខាងលើ។

បណ្តឹងតវ៉ាបែបនេះអាចត្រូវបានដាក់ជូនដោយសម្ងាត់ និងអនាមិក។